ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម
AGRICULTURAL AND RURAL DEVELOPMENT BANK
ដើម្បីកសិករនិងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម

# គម្រោងអាជីវកម្ម
# ចិញ្ចឹមទាគីរឈ្មោល





រៀបចំដោយ

**នាយកដ្ឋានគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃ**

**ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម**

ខែសីហា ឆ្នាំ២០២៦

023 220 811
023 220 810
095 416 878
# 168, Street 7, Prek Leap Village, Sangkat Prek Leap, Khan Chroy Changva, Phnom Penh

# មាតិកា


**១- សេចក្តីផ្តើម** ........ ១

**២-បច្ចេកទេសចិញ្ចឹម** ........ ១

២-១- ការជ្រើសរើសកូនទាគីរឈ្មោល........ ១

២-២- ការរៀបចំទីជម្រកទាគីរឈ្មោល........ ២

២-៣- ការថែទាំកូនទាគីរឈ្មោល........ ៤

២-៤- ចំណី និងទឹកសម្រាប់ទាគីរឈ្មោល........ ៥

**៣-ជំងឺ ការការពារ និងការថែរក្សាសុខភាពទាគីរឈ្មោល** ........ ៦

៣-១- ជំងឺផ្តាសាយបក្សី ........ ៦

៣-២- ជំងឺប៉េស្តទា ........ ៦

៣-៣- ជំងឺអាសន្នរោគ........ ៧

៣-៤- ជំងឺរលាកថ្លើមបង្កដោយវីរុសចំពោះទា........ ៨

**៤-តម្លៃ និងទីផ្សារ** ........ ៩

៤-១- តម្លៃ........ ៩

៤-២- ទីផ្សារ........ ៩

៤-៣- គម្រោងនៃការចំណាយលើការចិញ្ចឹមទាគីរឈ្មោលចំនួន ៣,៣៣០ក្បាល/វគ្គ ........ ៩

៤-៤- ការប្រមូលផលទាគីរឈ្មោល ........ ៩

**៥-ការវិភាគសេដ្ឋកិច្ច** ........ ៩

៥-១- ការវិភាគលើតម្លៃលក់ទាគីរឈ្មោលសាច់អាយុ២ខែ ........ ១១

៥-២- ការវិភាគទៅលើអត្រាបាត់បង់........ ១១

**៦-ហានិភ័យ វិធានការ និងអនុសាសន៍**........ ១២

**៧-សេចក្តីសន្និដ្ឋាន** ........ ១៣

## ១- សេចក្តីផ្តើម

ទា "គគីរ " គឺជាពូជទាមានរោមសម្បុរគគីរដែលប្រជាជនយើងនិយមហៅថា ទា "កាប " គឺជាពូជទាចិញ្ចឹមយកស៊ុតសម្រាប់ទាញីព្រោះជាពូជទាដែលផ្តល់ស៊ុតច្រើនជាងពូជទាដទៃ រីឯទាគគីរឈ្មោលគឺចិញ្ចឹមបំប៉នជាទាសាច់សម្រាប់ធ្វើម្ហូបអាហារដូចជា អាំង ខ្វៃ...ជាដើម ដែលមានសារធាតុខ្លាញ់តិច ជាតម្រូវការសម្រាប់អ្នកពុំចូលចិត្តខ្លាញ់ច្រើន។ ទាគគីរឈ្មោល ចិញ្ចឹមឆាប់ធំធាត់ដោយអាចប្រមូលផលក្នុងរយៈពេលត្រឹមតែពី ៧០ ទៅ ៨០ថ្ងៃ។ ការចិញ្ចឹមទាគគីរឈ្មោល គឺងាយស្រួលក្នុងការផ្តល់ចំណី ធន់ទ្រាំនឹងអាកាសធាតុបានល្អ។ ដើម្បីចិញ្ចឹមទាគគីរឈ្មោលទទួលបានជោគជ័យ និងទិន្នផលខ្ពស់ ទាមទារឱ្យកសិករត្រូវគិតគូរពីការជ្រើសរើសកូនទាពូជ របៀបថែទាំសុខភាព ជ្រើសរើសចំណីដែលមានសារធាតុចិញ្ចឹមគ្រប់គ្រាន់ របៀបផ្តល់ចំណីទៅតាមដំណាក់កាលនៃការលូតលាស់របស់ទា ការប្រើប្រាស់ថ្នាំ វ៉ាក់សាំង និងទីធ្លាចិញ្ចឹមមានលក្ខណៈសមស្រប។

## ២- បច្ចេកទេសចិញ្ចឹម

### ២-១-ការជ្រើសរើសកូនទាគគីរឈ្មោល

#### ក)-លក្ខណៈសម្គាល់ភិនភាគរបស់កូនទាគគីរឈ្មោលមាន÷

រោមពណ៌គគីរក្រម៉ៅពេលនៅតូច និងប្តូរជាពណ៌គគីរសុទ្ធនៅពេលធំឡើង មានកូនលិង្គតូចមួយនៅក្នុងរន្ធគូទ ចំពុះ និងជើងមានពណ៌ខ្មៅ មានដងខ្លួនវែង កវែង និងមូល ហើយមានអាកប្បកិរិយាស្ងប់ស្ងាត់ សម្លេងធំ។



ទាឈ្មោល ទាញី

#### ខ)-កត្តាសំខាន់ៗនៃការជ្រើសរើសកូនទាគគីរឈ្មោល ÷

-មានប្រភពច្បាស់លាស់ពីកន្លែងភ្ញាស់កូនទាត្រឹមត្រូវ

-ជាកូនទាគគីរឈ្មោលសុខភាពល្អ សល់ពីការរើសកូនទាញីចេញក្នុងតម្លៃខ្ពស់

-ជ្រើសរើសយកកូនទាមានដងខ្លួនវែង ដើបត្រង់ និងទងផ្ចិតស្ងួត

-មានរោមរាបជាប់ស្បែកភ្លឺរលោង និងភ្នែកភ្លឺថ្លា ជើងមានទ្រង់ទ្រាយល្អ មិនមានស្នាមរបួស

-ពូកែស៊ីចំណី ផឹកទឹក មានសុខភាពល្អ និងមិនមានជំងឺ ឬមិនធ្លាប់កើតជំងឺឆ្លង

ទាគីរឈ្មោលអាយុ ២,៥ខែ អាចមានទម្ងន់ចន្លោះពី ០,៩ទៅ ១,១គីឡូក្រាម/ក្បាល។



## ២-២-ការរៀបចំទីជម្រកទាគីរឈ្មោល

### ក)-មានផ្លាបិទជិត÷

-មានសុវត្ថិភាពការពារពីសត្វកាចសាហាវផ្សេងៗ

-កាត់បន្ថយការឆ្លងជំងឺពីខាងក្រៅ

-ងាយស្រួលក្នុងការគ្រប់គ្រង (ការផ្តល់ចំណី  ការផ្តល់វ៉ាក់សាំង...)

-ងាយស្រួលក្នុងការប្រមូលផល

### ខ)-ការសាងសង់រោងទា និងរៀបចំអនាម័យរោងទា÷

-សង់រោងទាពីសម្ភារៈងាយៗស្រួលរក

-រោងត្រូវបានធានាថាស្អាត សម្លាប់មេរោគ និងទុកចោលតិចបំផុត ១៤ថ្ងៃ

-ស្នូកទឹក ស្នូកចំណី ត្រូវធានាឱ្យល្អស្អាត និងស្ងួត

-ប្រើចំបើង ឬអង្កាមស្ងួត ហើយទន់ ដើម្បីទ្រាប់

-រោងត្រូវមានខ្យល់ចេញចូល តែចៀសវាងខ្យល់ត្រជាក់ប៉ះចំទាផ្ទាល់

-រោងត្រូវតែកម្តៅមុនពេលចូលកូនទា

-ត្រូវតែបាញ់ថ្នាំសម្លាប់មេរោគមុនពេលចូលកូនទា

-អង្កាម ត្រូវតែថ្មី បានរំងាប់មេរោគជាស្រេច ចំហ៊ុយមុន ៣ថ្ងៃចូលកូនទា

-ដាក់អង្កាមកម្រាសពី ៧-៨ស.ម

-ទីតាំងស្រួលថែទាំ ទូលាយ ដីមិនស្អិត មិនដក់ទឹក និងមិនមានទឹកហូរឆ្លងកាត់



### គ)-ការរៀបចំអាងទឹកសិប្បនិម្មិតសម្រាប់ទាគីរឈ្មោល

ករណីកន្លែងចិញ្ចឹមទាគីរឈ្មោលមិនមានត្រពាំងឬស្រះទឹកនោះ កសិករត្រូវតែរៀបចំអាងទឹក ដោយប្រើកៅស៊ូតង់សម្រាប់រៀបចំជាអាងទឹក ឬធ្វើអាងស៊ីម៉ងត៍មានរន្ធសម្រាប់បញ្ចេញបញ្ចូលទឹកឱ្យទាលេង



និងសម្រាប់លាងសម្អាតខ្លួនជាប្រចាំ ផ្ទៃបាតស្រះធ្វើរាងជម្រាលមុំ ៤៥ដឺក្រេ។ អ្នកចិញ្ចឹមទាគួរផ្លាស់ប្តូរទឹកអាងចេញពី ១ទៅ ២ដង/ថ្ងៃអាស្រ័យទៅលើភាពកង្វក់របស់ទឹក និងមិនត្រូវឱ្យទាលេងទឹកដែលមានកម្តៅក្តៅនោះទេ ។

## ២-៣-ការថែទាំកូនទាគីរឈ្មោល

-កូនទាគីរឈ្មោលទើបញាស់ត្រូវការផ្តល់ទឹក ចំណី និងមានខ្យល់អាកាសចេញចូលល្អ

-កូនទាត្រូវរក្សានៅក្នុងសីតុណ្ហភាពទៅតាមអាយុកាល ដែលចន្លោះពី ២៤ទៅ ៣៥អង្សារសេ

-កូនទាត្រូវចិញ្ចឹមកន្លែងមានសុវត្ថិភាព មិនមានសត្វកាចសាហាវ ឬសត្វផ្សេងៗមកបំផ្លាញ

-កូនទាអាយុក្រោម ៣ថ្ងៃ មិនត្រូវឱ្យទាប៉ះពាល់ទឹកឡើយ

-មិនត្រូវឱ្យកូនទានៅក្រោមទឹកភ្លៀងទេ ព្រោះកូនទាពុំអាចទប់ទល់នឹងអាកាសធាតុត្រជាក់បាន

-ដាក់កូនទាក្នុងទីធ្លាចិញ្ចឹម និងកន្លែងដេកស្របទៅតាមមាឌ អាយុ និងទំហំដងខ្លួន

-នៅរដូវរងារ គួរកម្តៅទារយៈពេល ៣-៤សប្តាហ៍ និងរដូវក្តៅ គួរកម្តៅទារយៈពេល ១ទៅ២សប្តាហ៍



**<u>ដង់ស៊ីតេដាក់ទាចិញ្ចឹមក្នុងទ្រុង</u>**÷

| អាយុទាគគីរឈ្មោល (សប្តាហ៍) | ដង់ស៊ីតេ (ក្បាល)/ម៉ែត្រការ៉េ |
|---|---|
| អាយុក្រោម ១សប្តាហ៍ | ២០-៣០ |
| អាយុចន្លោះពី ១ ទៅ៤សប្តាហ៍ | ១០-២០ |
| អាយុចាប់ពី ៤សប្តាហ៍ឡើង | ៣-៥ |

## ២-៤-ចំណី និងទឹកសម្រាប់ទាគគីរឈ្មោល

កូនទាចាប់ផ្តើមស៊ីចំណីក្រោយពេលញាស់ ហើយនឹងធំធាត់យ៉ាងឆាប់រហ័ស ដើម្បីលូតលាស់ ធំធាត់ ទាត្រូវការសារធាតុចិញ្ចឹមសំខាន់ៗដូចជា÷ទឹក ប្រូតេអ៊ីន ថាមពល វីតាមីន និងសារធាតុរ៉ែ ដែលមាននៅក្នុង បន្លែបៃតង គ្រាប់ធញ្ញជាតិ សំបកក្តាមខ្យង ខ្ចៅ ដង្កូវ និងសត្វល្អិតផ្សេងៗ។ល។

**កម្រិតប្រូតេអ៊ីនសម្រាប់ទាសាវឈ្មោលអាស្រ័យទៅតាមអាយុរបស់ទា មានដូចខាងក្រោម÷**

- ➢ កូនទាអាយុពី ១ថ្ងៃទៅ ៣សប្តាហ៍ត្រូវការកម្រិតប្រូតេអ៊ីនខ្ពស់ពី ២០ទៅ ២២%ដើម្បីចិញ្ចឹម សារពាង្គកាយ និងលូតលាស់យ៉ាងឆាប់រហ័ស
- ➢ ការផ្តល់ចំណីដល់កូនទាគគីរឈ្មោលតូចៗត្រូវធ្វើឡើងបន្ទាប់ពីកូនទាញាស់បាន ២៤ម៉ោង

- ផ្តល់ចំណីដល់កូនទា ៤-៥ដង/ថ្ងៃ
- លាយចំណីផ្សំឱ្យបានច្រើនមុខ
- បន្ថែមប្រូតេអ៊ីនដូចជាត្រីតូចៗ ឬជន្លេនកាត់តូចៗ ធ្វើឱ្យកូនទាឆាប់ធំធាត់លឿន
- បន្ថែមកូនក្តាម ខ្យង ជាប្រភពរ៉ែ និងផ្តល់បន្លែបៃតងដូចជាត្រកួន ឬចកបាយទា ជាប្រភពវីតាមីន
- កូនទាចូលចិត្តចំណីសើម ដូចជាចកបាយទា ដែលអាចស៊ីស្មើនឹងទម្ងន់វា
- ក្រោយពេលឱ្យចំណីរួចត្រូវដាក់កូនទាទៅក្នុងចានទាបដែលមានទឹក ១-១.៥ ស.ម ក្រោយពីឱ្យវាលេងទឹកសម្អាតខ្លួនរួច ដាក់ពួកវាទៅលើកម្រាលស្ងួត ឬកម្រាលអង្កាមដើម្បីសម្ងួតពួកវា មុននឹងដាក់វាចូលទៅក្នុងរោង ឬទ្រុងដើមវិញ។

**<u>តម្រូវការទឹក</u> ÷**

ទឹកមានសារៈសំខាន់ចូលរួមជួយដំណើរការលូតលាស់ ធ្វើឱ្យចំណីទន់ និងជួយដល់ការរំលាយអាហារ ការស្រូប និងការដឹកជញ្ជូនសារធាតុចិញ្ចឹមទៅគ្រប់សរីរាង្គ។

- ប្រើទឹកដែលមានលាយថ្នាំ ដូចជា÷ Glucose ចំនួន ៥ក្រាម +Vitamin C10% ចំនួន ២ក្រាម +Electrolyte ចំនួន ២ក្រាម លាយទឹក ចំនួន ១លីត្រ
- ដាក់ស្នូកទឹកឱ្យនៅក្បែរទា ត្រូវសង្កេតមើលចំពោះកូនទាណា ដែលមិនបានទៅក្បែរស្នូកទឹក
- ទឹកផឹកត្រូវពេញស្នូកល្អ ហើយត្រូវឧស្សាហ៍ផ្លាស់ប្តូរទឹកស្អាត ដើម្បីឱ្យទាផឹកទឹកឆ្អិនដែលបានកម្តៅក្នុងសីតុណ្ហភាព ១៨-២០ អង្សាសេ ក្នុងចំនួនគ្រប់គ្រាន់។

**<u>ចំណាំ</u>÷** ទាផឹកទឹកមិនគ្រប់គ្រាន់អាចបណ្តាលឱ្យស៊ីចំណីបានតិច ធំធាត់យឺត។ល។

## ៣- ជំងឺ ការការពារ និងការថែរក្សាសុខភាពទាគគីរឈ្មោល

ការចិញ្ចឹមកូនទាតែងជួបប្រទះជាញឹកញាប់នូវជំងឺមួយចំនួនដូចខាងក្រោម ÷

### ៣-១-ជំងឺផ្តាសាយបក្សី

អាចកើតមានឡើងលើទាគ្រប់វ័យ

**<u>រោគសញ្ញា</u>÷**

-ទាមានអត្រាងាប់ខ្ពស់ ងាប់លឿន (រោគសញ្ញា ឬស្លាកស្នាមមិនអាចកើតមាន)

- មានសភាពងងុយដេក ក្បាលសំយ៉ុងចុះប៉ះដី

-ភ្នែកឡើងស គ្របកភ្នែកហើម

-លាមករាគពណ៌ស

**<u>ចំណាំ</u>÷** *ជំងឺផ្តាសាយបក្សីពុំអាចព្យាបាលបាននោះទេ*

**<u>វិធីសាស្រ្តការពារ ÷</u>**

-កសិករត្រូវអនុវត្តវិធានការជីវសុវត្ថិភាពចំពោះហ្វូងទា

-បង្ខាំងបក្សីដែលនាំមកថ្មីឱ្យនៅដាច់ដោយឡែក មុនពេលដាក់ចូលក្នុងហ្វូង

-ទាអាចផ្ទុកជំងឺយ៉ាងស្ងៀមស្ងាត់ និងឆ្លងទៅបក្សីក្នុងភូមិ បណ្តាលឱ្យផ្ទុះជំងឺ

-ប្រើសំណាញ់ព័ន្ធជុំវិញ ដើម្បីចៀសវាងការប៉ះពាល់ជាមួយបក្សីព្រៃ

-វីរុសឆ្លងតាមរយៈស្បែកជើង សម្លៀកបំពាក់ និងដៃ ដូច្នេះកសិករត្រូវលាងដៃ ប្តូរសម្លៀកបំពាក់ និងសម្អាតស្បែកជើងជាមួយសាប៊ូមុនចូលទៅកសិដ្ឋានចិញ្ចឹម ដើម្បីកាត់បន្ថយការចម្លងមេរោគ។

## ៣-២-ជំងឺប៉េស្តទា

ជំងឺនេះបណ្តាលមកពីវីរុស មេរោគនៃជំងឺប៉េស្តចូលចិត្តរស់នៅក្នុងពោះវៀន និងកន្ទ្រោមពង ឬង ខាងក្រៅខ្លួនសត្វ វាចូលចិត្តរស់នៅក្នុងទឹក។

**<u>រោគសញ្ញា÷</u>**

-រយៈពេលបង្កជំងឺពី ២ទៅ១០ថ្ងៃ លើទាគ្រប់វ័យ

-អត្រាស្លាប់មានដល់ ១០០%

-ទាដែលមានវ័យចាស់ងាយទទួលជំងឺខ្លាំងជាងទាក្មេង

-ទាសំកុកដេកផ្ទាល់នឹងដីមិនសូវធ្វើចលនា ធ្លាក់ស្លាបមានសំបោរចេញពីច្រមុះ រង្វង់ភ្នែកក្រហមជាំ

-រាគ លាមកមានសណ្ឋានជាទឹក ឬរាគឈាម រោមមានប្រឡាក់ដី ឬឈាម

-ទាស្រេកទឹកខ្លាំង ទាច្រើនស្លាប់ដោយរមួលកទៅក្រោយ ឬទៅចំហៀងខ្លួន។

**<u>ការឆ្លងរាលដាល÷</u>**

-វីរុសនៃជំងឺប៉េស្តទាចេញពីដងខ្លួនសត្វមកក្រៅតាមលាមក ឬសារធាតុរាវផ្សេងៗចេញពីខ្លួនសត្វឈឺ ឬស្លាប់ ចូលក្នុងទឹក ចំណី ដែលបណ្តាលឱ្យឆ្លងទៅទាផ្សេងៗ និងសត្វកកេរដទៃទៀតនាំឱ្យមេរោគបង្កជំងឺពីកន្លែងមួយទៅកន្លែងមួយ។

**<u>វិធីសាស្រ្តការពារ និងព្យាបាល÷</u>**

-ពុំមានថ្នាំព្យាបាលទេ ព្រោះជំងឺនេះបណ្តាលមកពីវីរុស

-ត្រូវចាក់វ៉ាក់សាំងការពារជំងឺប៉េស្តទា

-ទិញកូនទាពីកន្លែងដែលគ្មានជំងឺ មានអនាម័យល្អភ្ជាស់ និងមេបាមានកម្មវិធីវ៉ាក់សាំងត្រឹមត្រូវ

-អនាម័យ (លាងសម្អាតស្នូកទឹក ស្នូកចំណី) ហាមសត្វបក្សីផ្សេងៗចូលក្នុងកន្លែងចិញ្ចឹមទា។

### ៣-៣-ជំងឺអាសន្នរោគ

ជាជំងឺបង្កឡើងដោយបាក់តេរី អត្រាស្លាប់ខ្ពស់ បង្ករោគលក្ខណៈមធ្យម ស្រួចស្រាវ និងស្រួចស្រាវខ្លាំង កើតឡើងលើទាគ្រប់វ័យទាំងអស់

**<u>រោគសញ្ញា÷</u>**

-ដំណើរល្មើយៗ និងខ្សោយកម្លាំង

-មិនសូវស៊ីចំណី ស្រេកទឹកខ្លាំង

-ទាគ្រវីក្បាលញឹកញាប់ និងរាគពណ៌លឿងខ្ចីលាយជាមួយទឹក

-ភ្នែកសើម និងច្រមុះមានស្លេស

-អត្រាបាត់បង់ចន្លោះពី ៥%ទៅ៣៥% ឆ្លងរហ័សតាមរយៈស្លេស និងការប៉ះពាល់ផ្ទាល់រវាងទាឈឺ និងទាជារស់នៅក្នុងហ្វូងតែមួយ

**<u>វិធីសាស្រ្តការពារ និងព្យាបាល ÷</u>**

-ចាក់វ៉ាក់សាំងការពារជម្ងឺអាសន្នរោគ(ចាក់សាច់ដុំទ្រូងឬសើរស្បែក)លើកូនទាអាយុ ២ទៅ ៣សប្តាហ៍

-ការប្រើប្រាស់ថ្នាំសម្រាប់ព្យាបាលពុំសូវមានប្រសិទ្ធភាពទេ ដោយសារមេរោគរីករាលដាលយ៉ាងឆាប់រហ័ស។

### ៣-៤-ជំងឺរលាកថ្លើមបង្កដោយវីរុសចំពោះទា

រលាកថ្លើមទា គឺជំងឺបង្កឡើងដោយវីរុសស្រួចស្រាវបំផុតលើកូនទាអាយុក្រោម ១សប្តាហ៍ បន្ទាប់ពីឆ្លងវីរុសនេះមានអត្រាស្លាប់ខ្ពស់ដល់ ៨០-៩៥%និងបង្កគ្រោះថ្នាក់ខ្លាំងចំពោះទាអាយុ៤សប្តាហ៍ចុះក្រោម។

**<u>រោគសញ្ញានៃជំងឺ÷</u>**

- ច្រើនកើតឡើងចំពោះកូនទា អាយុ ៤សប្តាហ៍ចុះក្រោម
- កូនទាអាយុក្រោម ១សប្តាហ៍មានអត្រាស្លាប់រហូតដល់ ៩៥%
- កូនទាដេកចំហៀងខ្លួន ហើយប្រកាច់ទធាក់ជើងទាំង២
- សន្លឹម មិនស៊ីចំណី ញ័រ ដួលផ្ងារក្បាលទៅក្រោយ និងស្លាប់ដោយបត់ក្បាលទៅក្រោយ





ថ្លើមធម្មតា



ផ្ទុកវីរុសរលាកថ្លើម

**ការការពារ**

- ចាក់វ៉ាក់សាំងតាមកម្មវិធី និងទិញកូនទាពីហ្វូងមេបាដែលបានចាក់វ៉ាក់សាំង
- កូនទា (Ducklings): បើមានអង់ទីគ័រពីកំណើតខ្ពស់ ចាក់នៅអាយុ ១ទៅ៧ថ្ងៃ បើតំបន់ផ្ទុះជំងឺខ្លាំង អាចចាក់ថ្ងៃទី១។

**ការព្យាបាលគាំទ្រសុខភាពទាទៅតាមរោគសញ្ញារួមមាន÷**

- ផ្តល់ទឹក លាយអេឡិចត្រូលីត (Electrolytes) ដើម្បីបង្ការការខ្វះជាតិទឹក
- ផ្តល់ថាមពល ដូចជាគ្លុយកូស (Glucose)
- ផ្តល់វីតាមីន Vitamin A, Vitamin D3, Vitamin E និង Vitamin C ដើម្បីពង្រឹងប្រព័ន្ធភាពស៊ាំ
- រក្សាសីតុណ្ហភាពបរិស្ថានឱ្យសមស្រប និងកាត់បន្ថយភាពតានតឹង (stress)
- ប្រើអង់ទីប៊ីយ៉ូទិក (Antibiotics) នៅពេលមានការឆ្លងបាក់តេរីឱកាសនិយម (secondary bacterial infection) តែត្រូវចាំថាមិនមានប្រសិទ្ធភាពលើវីរុសទេ។

## ៤-តម្លៃ និងទីផ្សារ

**៤-១-តម្លៃ÷** ឈ្មួញប្រមូលទិញទាគគីរឈ្មោលក្នុងតម្លៃបោះដុំពី ៧,០០០ ទៅ ១០,០០០រៀល/គ.ក្រ។

**៤-២-ទីផ្សារ÷** កសិករអាចលក់ទាគគីរឈ្មោលរស់ទៅឈ្មួញកណ្តាល ឬអ្នកលក់ទាអាំងផ្ទាល់ដែលមកយកដល់កសិដ្ឋាន។

**៤-៣-គម្រោងនៃការចំណាយលើការចិញ្ចឹមទាគគីរឈ្មោលចំនួន ៣,៣៣០ក្បាល/វគ្គ**

គម្រោងចិញ្ចឹមទាគគីរឈ្មោលនេះត្រូវបានក្រុមការងារចុះសិក្សានៅកសិដ្ឋានចិញ្ចឹមទាគគីរឈ្មោលនៅឃុំដំណាក់កន្ទួតខាងត្បូង ស្រុកកំពង់ត្រាច ខេត្តកំពត។

-ទំហំផ្ទៃកសិដ្ឋានសរុប÷ ០,៣ហិកតា

-ចំនួនវគ្គ/ឆ្នាំ÷ ៤វគ្គ/ឆ្នាំ (១វគ្គប្រើរយៈពេល ៧០ទៅ៨០ថ្ងៃនិងទុកទ្រុងឱ្យទំនេរ ១០ទៅ ២០ថ្ងៃដើម្បីសម្អាត បាញ់ថ្នាំសម្លាប់មេរោគ)

-ទំហំទ្រុង÷ ទទឹង១០ម៉ែត្រ និងបណ្តោយ៦០ម៉ែត្រ

-ទុនចំណាយពេលចាប់ផ្តើម÷ ២៦,៧៦១,៥៦៩រៀល ក្នុងនោះរួមមាន÷

| ចំណាយវិនិយោគលើការរៀបចំរោងទា សំណាញ់ និងឧបករណ៍សម្ភារៈផ្សេងៗ (ជារៀល) | ចំណាយលើការចិញ្ចឹម-ថែទាំ ពូជ ចំណី និងថ្នាំ (ជារៀល) | ចំណាយសរុប (ជារៀល) |
|---|---|---|
| **4,511,000** | **22,250,569** | **26,761,569** |

**៤-៤-ការប្រមូលផលទាគគីរឈ្នោលៈ**

ដោយផ្អែកលើនិន្នាការតម្លៃ និងអត្រាស្លាប់កូនទាអាយុក្រោម១សប្តាហ៍ពី ៥ ទៅ១៥%

-ទាគគីរឈ្នោលសាច់អាចមានទម្ងន់ពី ០,៩ទៅ ១,១គ.ក្រ/ក្បាល (ជាមធ្យមទម្ងន់ទាគគីរឈ្នោលសាច់ ១គ.ក្រ/ក្បាលសម្រាប់ការចិញ្ចឹមរយៈពេល ៧៥ថ្ងៃឬ ២,៥ខែ)

-អត្រាបាត់បង់មធ្យមអាចចន្លោះពី ៥%ទៅដល់១៥% គឺអាស្រ័យលើការថែទាំ ចំណី ទឹក និងពូជ

-*តាមរយៈការសិក្សា* កសិដ្ឋានចិញ្ចឹមទាគគីរឈ្នោលមានអត្រាបាត់បង់ ១០% នៃចំនួនទាសរុប

## ៥-ការវិភាគសេដ្ឋកិច្ច

លើការចិញ្ចឹមទាគគីរឈ្នោលចំនួន ៣,៣៣០ក្បាល/វគ្គ ទម្ងន់ជាមធ្យម ១គ.ក្រ/ក្បាល តម្លៃជាមធ្យម ៨,៥០០រៀល/ក្បាល។

| បរិយាយ | ឯកត្តា | ចំនួនឯកត្តា | តម្លៃ ១ឯកត្តា | ទឹកប្រាក់សរុប (៛) | ចំនួនសារវិលស់ | ទឹកប្រាក់សរុប (៛) |
|---|---|---|---|---|---|---|
| **១-ចំណូលសរុប/(២,៥ខែ)** | | | | | | **25,474,500** |
| ចំណូលពីការលក់ទាគគីរឈ្នោល | ក្បាល | 2,997 | 8,500 | 25,474,500 | | 25,474,500 |
| **២-ចំណាយសរុប = ចំណាយប្រែប្រួល + ចំណាយមិនប្រែប្រួល/ថេរ** | | | | | | **22,426,819** |
| **២.ក.ចំណាយប្រែប្រួល** | | | | | | **22,250,569** |
| កូនទាគគីរឈ្នោល | ក្បាល | 3,330 | 500 | 1,665,000 | | 1,665,000 |
| ចំណីកូនទា | គ.ក្រ | 7,340 | 2,093 | 15,365,669 | | 15,365,669 |
| ស្រូវ | គ.ក្រ | 2,850 | 1,000 | 2,850,000 | | 2,850,000 |
| ថ្លៃអគ្គិសនី | គី.វ៉ាត់ | 30 | 730 | 21,900 | | 21,900 |
| ថ្នាំ និងវិតាមីន | គ.ក្រ | 10 | 25,000 | 250,000 | | 250,000 |
| វ៉ាក់សាំងប៉េស្តទា | ដប | 3 | 50,000 | 150,000 | | 150,000 |

| | | | | | | |
|---|---|---|---|---|---|---|
| វ៉ាក់សាំងអាសន្នរោគ | ដប | 1.5 | 180,000 | 270,000 | | 270,000 |
| កម្លាំងពលកម្ម | ខែ | 2,5 | 640,000 | 1,600,000 | | 1,600,000 |
| ថ្នាំទម្លាក់សត្វល្អិត | កញ្ចប់ | 1 | 30,000 | 30,000 | | 30,000 |
| ថ្នាំសម្លាប់មេរោគ | ដប | 2 | 24,000 | 48,000 | | 48,000 |
| **២.ខ.ចំណាយមិនប្រែប្រួល/ថេរ (ក្នុង២,៥ខែ)** | | | | **4,511,000** | | **176,250** |
| រោងទាគឺរឈ្មោល(ទទឹង១០ម៉ែត្រ បណ្ដោយ៦០ម៉ែត្រ) | រោង | 1 | 4,000,000 | 4,000,000 | 40 | 100,000 |
| សំណាញ់ព័ទ្ធជុំវិញបរិមាណទ្រុង | គ.ក្រ | 5 | 25,000 | 125,000 | 30 | 4,167 |
| កម្រាល(ចំបើង និងអង្កាម) | ដុំ | 7 | 3,000 | 21,000 | 1 | 21,000 |
| ស្នូកទឹក | ចំនួន | 4 | 80,000 | 320,000 | 30 | 10,667 |
| ស្នូកចំណី | ចំនួន | 10 | 500 | 5,000 | 12 | 417 |
| អំពូលកម្ដៅ | ចំនួន | 10 | 4,000 | 40,000 | 1 | 40,000 |
| **៣-ចំណេញសរុប** | | | | | | **3,047,682** |
| **ថ្លៃដើមសរុបទាគឺរឈ្មោល ១ក្បាល= ចំណាយសរុប/ចំនួនទាគឺរឈ្មោលសរុប** | | | | | | **7,483** |
| **ចំណេញលើទាគឺរឈ្មោល ១ក្បាល= តម្លៃលក់ចេញ-តម្លៃដើមក្នុង១ក្បាល** | | | | | | **1,017** |

**៥-១-ការវិភាគលើតម្លៃលក់ទាគឺរឈ្មោលសាច់អាយុ២,៥ខែ ដោយផ្អែកលើនិន្នាការតម្លៃ÷**

- ចន្លោះពីខែកុម្ភៈ ដល់ ខែមេសា តម្លៃជាមធ្យម ៩,៥០០ រៀល/ក្បាល
- ចន្លោះពីខែឧសភា ដល់ ខែមិថុនា តម្លៃជាមធ្យម ៨,០០០ រៀល/ក្បាល
- ចន្លោះពីខែកក្កដា ដល់ ខែមករា តម្លៃជាមធ្យម ៨,៥០០ រៀល/ក្បាល

| ចំនួនទាគឺរឈ្មោល | តម្លៃ/ក្បាល | ចំណូលសរុប | ចំណាយសរុប | ចំណេញសរុប | ភាគរយ |
|---|---|---|---|---|---|
| 2,997 | 8,000 | 23,976,000 | 22,426,819 | 1,549,182 | 6.91% |
| 2,997 | 8,500 | 25,474,500 | 22,426,819 | 3,047,682 | 13.59% |
| 2,997 | 9,500 | 28,471,500 | 22,426,819 | 6,044,682 | 26.95% |

## ៥-២-ការវិភាគទៅលើអត្រាបាត់បង់(៥%ដល់ ៣៥%)

| អត្រាបាត់បង់(%) | ចំនួន(ក្បា) | ចំនួនបាត់បង់(ក្បា) | ចំនួនទាសល់(ក្បា) | តម្លៃ/ក្បា(៛) | ចំណូលសរុប(៛) | ចំណាយសរុប(%) | ចំណេញសរុប(៛) |
|---|---|---|---|---|---|---|---|
| 5% | 3,330 | 167 | 3,164 | 8,500 | 26,889,750 | 22,426,819 | 4,462,932 |
| 10% | 3,330 | 333 | 2,997 | 8,500 | 25,474,500 | 22,426,819 | 3,047,682 |
| 15% | 3,330 | 500 | 2,831 | 8,500 | 24,059,250 | 22,426,819 | 1,632,432 |
| 20% | 3,330 | 666 | 2,664 | 8,500 | 22,644,000 | 22,426,819 | 217,182 |
| 25% | 3,330 | 833 | 2,498 | 8,500 | 21,228,750 | 22,426,819 | 1,198,069 |
| 30% | 3,330 | 999 | 2,331 | 8,500 | 19,813,500 | 22,426,819 | 2,613,319 |
| 35% | 3,330 | 1,166 | 2,165 | 8,500 | 18,398,250 | 22,426,819 | 4,028,569 |

## ៦-ហានិភ័យ វិធានការ និងអនុសាសន៍÷

តាមរយៈនៃការចុះស្វែងយល់ដល់កសិដ្ឋាន កសិករចិញ្ចឹមទាគីរឈ្មោល អាចជួបប្រទះហានិភ័យមួយចំនួនជាយថាហេតុលើដំណើរការចិញ្ចឹមទាគីរឈ្មោល ដែលនាំឱ្យបង្កផលវិបាក និងប៉ះពាល់ដល់សមត្ថភាពផលិតកម្ម ដូចនេះកសិករគួររៀបចំផែនការជាក់លាក់ដើម្បីកាត់បន្ថយ ឬគ្រប់គ្រងលើហានីភ័យប្រកបដោយប្រសិទ្ធភាពខ្ពស់។ ហានិភ័យទាំងនោះរួមមាន÷

| ល.រ | ប្រភេទហានិភ័យ | ការពិពណ៌នាពីហានិភ័យ | វិធានការ និងអនុសាសន៍ |
|---|---|---|---|
| ១ | ហានិភ័យផលិតកម្ម | កូនទាគីរដែលមានជំងឺតពូជពីមេបា និងកូនទាគីរឈ្មោលដែលមានសុខភាពខ្សោយដឹកជញ្ជូនយូរពេក | -សិក្សាពីប្រវត្តិកសិដ្ឋានលក់ពូជឱ្យបានច្បាស់លាស់អំពីមេបាពូជ<br>-ត្រូវរើសកូនទាគីរឈ្មោលដែលមានសុខភាពល្អមានទំហំប៉ុនៗគ្នា មានរោមភ្លឺរលោង មិនស្វិតជើង<br>-សន្ទាក់ជើងល្អ ដំណើររហ័សរហួន ជៀសវាងពូជជាន់ឈាម<br>-មានកែវភ្នែកភ្លឺថ្លា<br>-តាមដានទម្ងន់មេបា និងប្រវត្តិដើមនៃការបង្កាត់ពូជ |

| | | | |
|---|---|---|---|
| | | កង្វះខាតទីធ្លា ពុំមានស្រះទឹកសម្រាប់ទាហែលលេង និងខ្វះទឹកស្អាតសម្រាប់ផឹក | -មានទំហំសមាមាត្រនឹងចំនួនទាគីរឈ្មោល<br>-មានរៀបចំស្រះទឹកសម្រាប់កូនទាហែលលេង<br>-មានទឹកស្អាតសម្រាប់ផឹកគ្រប់គ្រាន់ជាប្រចាំ<br>-រៀបចំកម្រាលទ្រុងស្ងួតល្អ ពិសេសពេលកូនទានៅតូច<br>-ផ្តល់កម្តៅឱ្យបានគ្រប់គ្រាន់ |
| ២ | **ហានិភ័យទីផ្សារ** | តម្លៃទីផ្សារទាគីរសាច់ប្រែប្រួលមិនច្បាស់លាស់ | -ស្វែងរកទីផ្សារ ឬឈ្មួញប្រមូលទិញឱ្យបានច្រើន<br>-ស្វែងរកហាង ភោជនីយដ្ឋានដែលមានតម្រូវការជាប្រចាំ និងលទ្ធភាពផ្គត់ផ្គង់ច្បាស់លាស់<br>-រកទីផ្សារលក់រាយក្នុងតំបន់ទៅអ្នកបរិភោគផ្ទាល់ |
| ៣ | **ហានិភ័យ ហិរញ្ញវត្ថុ** | ខ្វះថវិកានៅក្នុងដំណើរការចិញ្ចឹម ពេលខ្លះត្រូវបង្ខិចិត្តលក់ទាំងទាពុំទាន់គ្រប់ទម្ងន់ | -មានផែនការអាជីវកម្មច្បាស់លាស់<br>-មានទុនបម្រុងក្រៅពីទុនវិនិយោគ<br>-ត្រូវរកទុនឥណទានដែលមានអត្រាការប្រាក់ទាបសមរម្យ<br>-កំណត់បរិមាណទាដែលត្រូវចិញ្ចឹមទៅតាមទំហំទុន<br>-ដាក់ទាគីរឈ្មោលចិញ្ចឹមក្នុងទ្រុងនូវបរិមាណសមស្រប ដោយដាក់ចិញ្ចឹមវិលជុំ |
| ៤ | **ហានិភ័យ បរិស្ថាន** | មានក្លិនស្អុយសាយភាយទៅអ្នករស់នៅជិតខាង | -ត្រូវចិញ្ចឹមនៅក្នុងចម្ការ ឬឆ្ងាយពីផ្ទះប្រជាជនរស់នៅ<br>-ត្រូវធ្វើអនាម័យជាប្រចាំ និងរៀបចំប្រព័ន្ធជីវសុវត្ថិភាព |

## ៧-សេចក្តីសន្និដ្ឋាន

ទាគីរឈ្មោលងាយស្រួលចិញ្ចឹម មិនរើសចំណី ធំធាត់លឿន ធន់ខ្លាំងទៅនឹងអាកាសធាតុ មានទីផ្សារល្អនៅរដូវបុណ្យទាន ពិសេសចន្លោះពីខែមករា ដល់ខែមេសា។ តាមការចុះសិក្សាជាក់ស្តែងការចិញ្ចឹមទាគីរឈ្មោលរបស់កសិករនៅខេត្តកំពត ចំនួន ៣,៣៣០ក្បាល ដោយប្រើពេល២,៥ខែ/វគ្គ ទទួលបានទម្ងន់ជាមធ្យម ១គ.ក្រ/ក្បាល ស្មើនឹង ២,៩៩៧ក្បាល (អត្រាបាត់បង់ ១០%) ដោយចំណាយថ្លៃដើមផលិត ៧,៤៨៣រៀល/ក្បាល ទទួលបានប្រាក់ចំណេញប្រមាណ ១,០១៧រៀល/ក្បាល។ ក្នុង ១វគ្គកសិករអាចទទួលបានប្រាក់ចំណេញជាង ៣លានរៀល សម្រាប់តម្លៃទូទៅ និងរដូវកាលចូលឆ្នាំចិន ឬបុណ្យទានធំៗ កសិករអាចលក់ចេញក្នុងតម្លៃ ៩,៥០០រៀល/ក្បាល ដែលអាចទទួលបានប្រាក់ចំណេញ ជាង ៦លានរៀល/វគ្គ ប៉ុន្តែប្រាក់ចំណេញអាចប្រែប្រួលអាស្រ័យលើអត្រាបាត់បង់ និងតម្លៃលក់លើទីផ្សារ។ ដើម្បីទទួលបានប្រាក់ចំណេញច្រើន កសិករគួរគិតគូរលើកត្តាចាំបាច់មួយចំនួនដូចជា ការជ្រើសរើសកូនទាពូជ ការថែទាំដោយធ្វើ

អនាម័យស្នូកទឹក ចំណី និងអាងទឹកសម្រាប់ទាចុះសម្អាតខ្លួន គុណភាពចំណីសមស្របនឹងតម្លៃ ធ្វើកម្មវិធីវ៉ាក់សាំងឱ្យបានទៀងទាត់ និងមានទីផ្សារបោះដុំច្បាស់លាស់។

**ប្រភពនៃការសិក្សាស្រាវជ្រាវ**

១/ កសិករចិញ្ចឹមទាគគីរឈ្មោលនៅឃុំដំណាក់កន្ទួតខាងត្បូង ស្រុកកំពង់ត្រាច ខេត្តកំពត

២/ បទពិសោធន៍ជោគជ័យលើមុខរបរចិញ្ចឹមទា (នាយកដ្ឋានផ្សព្វផ្សាយកសិកម្មរុក្ខាប្រមាញ់ និងនេសាទ)

៣/ វិធីសាស្រ្តផ្តល់ចំណីទាយកស៊ុតរបស់ក្រុមហ៊ុនចំណីសត្វ ឆ្នាំ ២០១៦

៤/ ការចិញ្ចឹម និងគ្រប់គ្រងទានៅជនបទ (នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម)